ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Chambres extraordinaires au sein
des tribunaux cambodgiens

# សេចក្តីប្រកាសព័ត៌មាន

## សហចៅក្រមស៊ើបអង្កេត ផ្សព្វផ្សាយឯកសារនៃសំណុំរឿងស៊ើបអង្កេតជាសាធារណៈ

ដោយយោងតាមសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០០៩ ស្តីពីការផ្សព្វផ្សាយបន្ថែមនូវឯកសារស៊ើបអង្កេត និងស្របតាមវិធាន ៥៦(២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេត នៅក្នុងក្របខណ្ឌនៃនីតិវិធីដែលកំពុងដំណើរការ បានសម្រេចធ្វើការផ្សព្វផ្សាយជាសាធារណៈនូវឯកសារនៃសំណុំរឿងទាំងអស់ទាក់ទិននឹងបញ្ហាប្រើប្រាស់ជាយថាហេតុនៃចម្លើយសារភាព ដែលទទួលបានដោយការធ្វើទារុណកម្មនៅក្នុងរបបខ្មែរក្រហម។ ឯកសារទាំងនេះ រួមមានជាអាទិ៍ ៖

- សំណើសុំដំបូងរបស់មេធាវីការពារក្តី ស្នើកុំឲ្យទទួលចម្លើយសារភាពប្រភេទនេះ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩
- សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩

សេចក្តីសម្រេចរបស់ចៅក្រមលើបញ្ហានេះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈផងដែរ។

ឯកសារទាំងអស់នេះ អាចរកបានដោយចុចលើ៖

(http://www.eccc.gov.kh/khmer/court_doc.list.aspx?courtDocCat=case_docs)
រួចវាយលេខកូដ “D130” នៅក្នុងប្រអប់លេខឯកសារដើម្បីរុករកឯកសារ។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បន្ទាប់ពីការផ្សព្វផ្សាយឯកសារនេះ នឹងមានការផ្សព្វផ្សាយផ្សេងៗទៀតជាបន្តបន្ទាប់។ម្យ៉ាងទៀត សហចៅក្រមស៊ើបអង្កេត សូមរំលឹកថា របាយការណ៍តុលាការ ដែលផ្សព្វផ្សាយលើគេហទំព័ររបស់អង្គជំនុំជម្រះ មានព័ត៌មានប្រចាំខែថ្មីៗស្ដីពីសកម្មភាពនៃកិច្ចស៊ើបសួរ៖

(http://www.eccc.gov.kh/khmer/publications.courtReport.aspx)

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៩